## រឿងទី១០៖ ប្រស្នាអំពីប្រាក់ណែន

**ខគម្ពីរ៖ ម៉ាថាយ២៥៖២១**

ម្ចាស់ក៏ពោលទៅគាត់ថា: "ល្អហើយ! អ្នកបំរើដ៏ប្រសើរ មានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់និងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុសត្រូវលើកិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ"។



កាលពីយូរលង់ណាស់មកហើយ មានមនុស្សម្នាក់រៀបនឹងចេញដំណើរទៅស្រុកឆ្ងាយ។
មុនពេលចេញដំណើរ គាត់ហៅពួកអ្នកបម្រើមកប្រគល់ទ្រព្យសម្បត្តិឱ្យ រួចផ្តាំថា៖
«យើងនឹងឱ្យទ្រព្យសម្បត្តិទៅឯង ចូរយកវាទៅធ្វើជំនួញឱ្យបានចម្រើនឡើង ក្នុងកំឡុងពេលដែលយើងមិននៅ»។
គាត់បានប្រគល់ប្រាក់ឱ្យអ្នកបម្រើទីមួយ ប្រាំណែន, អ្នកបម្រើទីពីរ ពីរណែន, អ្នកបម្រើទីបី មួយណែន។
ក្រោយពេលដែលចៅហ្វាយបានចាកចេញទៅ អ្នកបម្រើទីមួយ និងអ្នកបម្រើទីពីរ បានយកប្រាក់នោះទៅរកស៊ី។
ពួកគេបានខិតខំធ្វើការងារយ៉ាងស្មោះត្រង់ ដោយសង្ឃឹមថាម្ចាស់នឹងរីករាយ ។
អ្នកបម្រើទីមួយ បានយកប្រាក់ប្រាំណែននោះទៅរកស៊ី ចំណេញបានប្រាំណែន
អ្នកបម្រើទីពីរក៏ដូច្នោះដែរ គាត់យកប្រាក់ណែននោះទៅរកស៊ី ចំណេញបានពីរណែនទៀត។
ចុះអ្នកបម្រើទីបី បានធ្វើយ៉ាងដូចម្តេច? ប៉ុន្មានខែក្រោយមក ម្ចាស់ក៏បានវិលត្រឡប់មកវិញ។
អ្នកបម្រើទាំងបី បានទៅរកម្ចាស់ ហើយរៀបរាប់កិច្ចការដែលខ្លួនបានធ្វើ។
ម្ចាស់បានឃើញអ្នកបម្រើទីមួយ និងអ្នកបម្រើទីពីរបានធ្វើកិច្ចការរបស់ខ្លួនយ៉ាងល្អ គាត់រីករាយជាពន់ពេក។
គាត់ថែមទាំងបានសន្យាទៀតថា នៅថ្ងៃមុខគាត់នឹងដាក់កិច្ចការយ៉ាងច្រើនទៀតឱ្យពួកគេ។

ចុងក្រោយ អ្នកបម្រើទីបីក៏បានចូលមក ហើយជម្រាបថា៖



«លោកម្ចាស់! ខ្ញុំប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់។ លោកតែងច្រូតយកផលពីស្រែដែលលោកមិនបានសាបព្រោះ ហើយប្រមូលយកផលពីដំណាំដែលលោកមិនបានដាំ។ ខ្ញុំប្របាទបានយកប្រាក់ដែលលោកប្រគល់ឲ្យ ទៅជីកដីកប់ ព្រោះខ្ញុំប្របាទភ័យខ្លាចពេក។ ឥឡូវនេះ សូមលោកម្ចាស់យកប្រាក់របស់លោកវិញចុះ»។
ឮហើយ ម្ចាស់ខឹងខ្លាំងណាស់។

នៅទីបំផុត អ្នកបម្រើដែលបានខិតខំប្រើអំណោយទានដែលបានទទួល មានពេលវេលាដ៏មានសុភមង្គលជាមួយនឹងម្ចាស់របស់ខ្លួន រីឯអ្នកបម្រើដ៏ខ្ជិលច្រអូសដែលមិនខិតខំធ្វើការវិញយំសោកដោយត្រូវម្ចាស់បណ្តេញចេញ។

**សកម្មភាពទី១** **សូមគណនាប្រមាណវិធីខាងក្រោម ដើម្បីស្វែងរកចម្លើយ។**

a. តើម្ចាស់បានប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួន ដល់អ្នកបម្រើប៉ុន្មាននាក់? (5 + 2) - 4 = __________

b. តើម្ចាស់បានប្រគល់ប្រាក់ណែនចំនួនប៉ុន្មាន ដល់អ្នកបម្រើម្នាក់ៗ?

1. 1 + (10÷2) - 1= __________
2. 2 - (20÷10) + 2= __________
3. 1÷1= __________

c. តើអ្នកបម្រើម្នាក់ៗយកប្រាក់ទៅរកស៊ីចំណេញបានម្នាក់ប៉ុន្មាន?

1. 150÷30= __________
2. 240÷120= __________
3. 10-10= __________

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (ម៉ាថាយ២៥៖២១)

**ម្ចាស់ក៏ពោលទៅគាត់ថាៈ «ល្អហើយ! អ្នកបំរើដ៏ប្រសើរ មានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកអោយមើលខុសត្រូវលើកិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ»។**

**សកម្មភាពទី២**

សូមគូររូបសម្ភារៈផ្សេងៗ ដែលខ្លួនអាចយកទៅលក់ដូរបាន នៅលើកន្ត្រកទទេ និងនៅលើតុ។
សូមឧទាហរណ៍អំពីអ្វីដែលអ្នកបម្រើបានធ្វើ។

